ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៧២/១៩-០១-២០១១
សាលដីកា
លេខ:៦៩ក្រ៣(ច)/២៥-១០-២០១១

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បាន បើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី១១-១០-២០១១ ដែលមាន សមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សា**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៧២ ចុះថ្ងៃទី១៩-០១-២០១១ រវាង:

១-ឈ្មោះ [redacted] គង់ ហៅ ភិរម្យ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ មុខរបរសន្តិសុខ កើតនៅភូមិរកាខ្ពស់ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុនគ្មាន ។

មានមេធាវីការពារលោក [redacted] ហេង

២-ឈ្មោះ [redacted] សារីយ៉ា ហៅ យោ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរឥស្លាម មុខរបរសន្តិសុខ កើតនៅភូមិច្រាំងចំរេះ សង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] ម៉ារីយ៉ុំ (ស)នៅលីវ ទោសពីមុនគ្មាន ។ ៥/





Scanned with CamScanner

ជាប់ចោទពីបទៈ ប្លន់ (លួចមានគួកន) ប្រព្រឹត្តទៅនៅចំណុចរោងចក្រផលិតស្បែកជើង អេ ស៊ី អេន អ៊ី ស្ថិតក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០៥.២០១០ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-ឈ្មោះ [redacted] ដេត ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ កើតនៅភូមិព្រៃក្រាយ ឃុំតាំងដូង ស្រុកបាទី ខេត្តតាកែវ សានាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃភូមិ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ។

ជាប់ចោទពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តទៅនៅចំណុចរោងចក្រផលិតស្បែកជើង អេ ស៊ី អេន អ៊ី ស្ថិតក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០៥.២០១០ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈីវសុង ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិស្រែតាចេង ឃុំស្រែតាចេង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង មុខរបរប្រធានរដ្ឋបាលរោងចក្រ សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅផ្ទះលេខ [redacted] ។

តាមពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៥.១១.២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] គង់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ១២៥ (ក្រ.១) ចុះថ្ងៃទី២៧.១០.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ លើចំណុចនៃសាលក្រមទាំងមូល ។

ឯរឿងហេតុមានដូចតទៅៈ

កាលពីថ្ងៃទី២៥.០៥.២០១០ មានករណីលួចយកស្បែកគោ ដែលប្រើសម្រាប់ច្នៃធ្វើស្បែកជើងមួយ បានកើតឡើងនៅចំណុចរោចក្រផលិតស្បែកជើង អេស៊ីអេនអ៊ី ស្ថិតក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលប្រព្រឹត្តឡើងដោយជនល្មើសឈ្មោះ [redacted] គង់ ហៅ ភិរម្យ និងឈ្មោះ [redacted] សារ៉ៃយ៉ា ហៅ យោ ជាសន្តិសុខយាមនៅរោងចក្រ បានធ្វើសកម្មភាពលួចស្បែកគោ ដែលប្រើសម្រាប់ច្នៃធ្វើស្បែកជើងចំនួនមួយដុំ ហើយបានយកទៅលាក់ទុកនៅក្បែររោងចក្រនេះ រួចបានយកលក់ឲ្យទៅឈ្មោះ [redacted] ដេត បានប្រាក់ចំនួន ៦០ ០០០ ៛ (ប្រាំមួយម៉ឺនរៀល) ។

**បានឃើញ**សាលក្រមព្រហ្មទណ្ឌលេខៈ១២៥(ក្រ.៥) ចុះថ្ងៃទី២៧.១០.២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើៈ

១៥៨



Scanned with CamScanner

ក.ឈ្មោះ [redacted] គង់ ហៅ ភិរម្យ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ

ខ.ឈ្មោះ [redacted] សារីយ៉ា ហៅ យោ ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិខ្មែរឥស្លាម

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទៈ ប្លន់ (លួចគ្នាច្រើន) ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើង អេ ស៊ី អេន អ៊ី ស្ថិតក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០៥.២០១០ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា០៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

គ.ឈ្មោះ [redacted] ដេត ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០១ឆ្នាំ(មួយឆ្នាំ) ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចរោងចក្រផលិតស្បែកជើងអេ ស៊ី អេន អ៊ី ស្ថិតក្នុងភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥.០៥.២០១០ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៥១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០.១០.២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៧.១០.២០១០ ចំពោះជនជាប់ចោទឈ្មោះ [redacted] គង់ ហៅ ភិរម្យ , [redacted] សារីយ៉ា ហៅ យោ និងឈ្មោះ [redacted] ដេត មេធាវីការពារជនជាប់ចោទ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញរបាយការណ៍ ចុះថ្ងៃទី៣១-០៥-២០១១របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ។

បានឃើញសេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៦-០៧-២០១១ របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

នាពេលសវនាការ

តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] គង់ ហៅ ភិរម្យ ឆ្លើយថាៈ នៅថ្ងៃធ្វើការងារខ្លួនបានចូលទៅធ្វើការក្នុងរោងចក្រជាធម្មតា ហើយក៏ចេញពីធ្វើការងារជួបឈ្មោះ [redacted] សារីយ៉ា ជាសន្តិសុខបានពឹងពាក់ឲ្យយកឥវ៉ាន់ទៅឲ្យឈ្មោះ [redacted] ដេត ។ ខ្លួនពុំបានចូលរួមធ្វើសកម្មភាពលួចស្បែកគោជាមួយឈ្មោះ [redacted] សារីយ៉ា ទេ ។ ក្នុងការដែលឈ្មោះ [redacted] សារីយ៉ា បានពឹងពាក់ឲ្យខ្លួនយកឥវ៉ាន់ដាក់ស្បោងខ្មៅទំហំប្រវែងកន្លះម៉ែត្រ ទម្ងន់ស្រាលដែលបានដាក់ក្នុងដីឡូត៍ក្បែររោងចក្រ ដើម្បីយកទៅឲ្យឈ្មោះ ផន ហើយឈ្មោះ [redacted] សារីយ៉ា ជាសន្តិសុខរោងចក្រស្បែកជើង ។ តែក្នុងការលួចស្បែកគោពីរោងចក្រឈ្មោះ [redacted] សារីយ៉ា ពុំប្រាប់ឲ្យខ្លួនបានដឹងទេ ។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ខ្លួនបានយកឥវ៉ាន់ទៅឲ្យ ផន ក្នុងរយៈពេល១ថ្ងៃនេះ ហើយថ្ងៃទី២០.២៥ ខែឧសភា ឆ្នាំ២០១០ ខ្លួនពុំបានយកឥវ៉ាន់ឲ្យទេ ។ ខ្លួនជាកម្មករលីសែងប៉ាតង់ឲ្យគេក្នុងរោងចក្រ ត្រូវសមត្ថកិច្ចឃាត់ខ្លួនកំពុងកាន់ឥវ៉ាន់ស្បែកគោដាក់ក្នុងថង់ខ្មៅ ។ ប៉ុន្តែឈ្មោះ [redacted] សារីយ៉ា បានស្គាល់គ្នារយៈពេល១ខែ តែងតែយកឥវ៉ាន់ជាស្បែកគោទៅឲ្យឈ្មោះ ផន តាមការចង្អុលបង្ហាញរបស់ឈ្មោះ រីម សារីយ៉ា ។ ចំណែកថង់ខ្មៅដែលដាក់ឥវ៉ាន់ជាស្បែកគោ ពុំទាន់ផលិតជាស្បែកជើង-



Scanned with CamScanner

ហើយចង់បានត្រូវឈ្មោះ [redacted] សារីយ៉ា យកមកដាក់មុខប៉ុស្តិ៍សន្តិសុខយាម និងធ្លាប់ពឹងពាក់ខ្លួនជាច្រើនលើក កន្លងមកពុំទាន់បានឲ្យកំរៃយកស្បែកគោទៅឲ្យគេនៅឡើយទេ ។ ខ្លួនពុំដឹងចង់ដែលឈ្មោះ [redacted] សារីយ៉ា ពឹងពាក់ឲ្យយកទៅឲ្យឈ្មោះ ផន មានស្បែកគោទម្ងន់ប៉ុន្មានទេ ហើយចម្លើយដែលឆ្លើយនៅខាងនគរបាលត្រូវគេបង្ខំឲ្យឆ្លើយ បានវាយបណ្តាលឲ្យហូរឈាម ក៏បានផ្តិតមេដៃលើកំណត់ហេតុតែម្តង ។

តាមអំណានចម្លើយជនជាប់ចោទឈ្មោះ[redacted]សារីយ៉ា ឆ្លើយថាៈ ខ្លួនជាសន្តិសុខរោងចក្រផលិតស្បែកជើង អេស៊ីអិនអ៊ី ក៏បានយកស្បែកគោចេញពីរោងចក្រពឹងពាក់ឲ្យឈ្មោះ សុខ គង់ យកឥវ៉ាន់ទៅឲ្យឈ្មោះ [redacted] ដេត ហើយឥវ៉ាន់ស្បែកគោពុំទាន់ផលិតជាស្បែកជើងនៅឡើយទេ ។ តែក្នុងពេលយប់ខ្លួនជាសន្តិសុខយាមរោងចក្រ បានឡើងតាមចន្លោះបង្អួចរោចក្រ ដើម្បីលួចស្បែកគោតែម្នាក់ឯង ក្នុងមួយដងចំនួន៨ដុំ ហើយមួយដុំទម្ងន់ចំនួន៨គីឡូក្រាម លក់១គីឡូក្រាមតំលៃ៥០ ០០០ រៀល ទៅ ៦០ ០០០ រៀល បានយកស្បែកគោចំនួន៨ដុំ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង២.០០នាទី កណ្តាលអធ្រាត្រ ក៏យកមកទុកក្រៅជីឡូតិ៍មួយកន្លែងទំនេរក្បែររោងចក្រ ហើយក៏ពឹងពាក់ឈ្មោះ [redacted] គង់ ឲ្យយកទៅឲ្យគេមិនស្គាល់ឈ្មោះ ។ តែឈ្មោះ[redacted]គង់ ពុំបានដឹងថាជាស្បែកគោ គ្រាន់តែខ្លួនប្រាប់ថា របស់ជាដុំក្រណាត់មូលជាដុំ ហើយទៅយកក្នុងវេលាម៉ោង២.០០នាទីរសៀលដើម្បីយកទៅឲ្យឈ្មោះ [redacted] ដេត ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ចំពោះថ្ងៃទី២០, ២៥ ខែឧសភា ឆ្នាំ២០១០ ខ្លួនពុំបានចូលទៅលួចស្បែកគោពីក្នុងរោងចក្រស្បែកជើងទេ ហើយឈ្មោះ [redacted]ដេត មិនមែនជាកម្មកររោងចក្រស្បែកជើង ជាអ្នកដើរទិញកំទេចក្រណាត់តែប៉ុណ្ណោះ ។ តែពេលខ្លួនទៅលួចឥវ៉ាន់ជាស្បែកគោ បានច្រកបាវយកមកលាក់ទុកក្នុងដីឡូតិ៍ដែលនៅជាប់រោងចក្រ ហើយឈ្មោះ សុខ គង់ ពុំបានចូលរួមធ្វើសកម្មភាពលួចស្បែកគោក្នុងរោងចក្រជាមួយខ្លួនទេ ។

តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ដេត ឆ្លើយថាៈ ខ្លួនពិតជាទិញស្បែកគោពីឈ្មោះ [redacted] គង់ ក្នុង១គីឡូក្រាមតំលៃ៨ ០០០ រៀល ហើយទិញបានចំនួន២៦គីឡូក្រាម ក្នុងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង១១ថ្ងៃត្រង់ ពុំទាន់បានទូទាត់ប្រាក់ឲ្យឈ្មោះ [redacted]គង់ ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ តែក្នុងពេលនោះឈ្មោះ [redacted]គង់ បានទូរស័ព្ទឲ្យឡើងពីខេត្តតាកែវ មកយកស្បែកគោម្តុំរោងចក្រ១០០ជាន់ ហើយរូបខ្លួន និងឈ្មោះ[redacted]វុទ្ធី បានជិះម៉ូតូយកស្បែកគោបំរុងជិះចេញក៏ត្រូវផ្នែករដ្ឋបាលរោចក្រជិះមុកម៉ូតូដើម្បីឃាត់ខ្លួន តែឈ្មោះ [redacted] វុទ្ធី ពុំបានចូលរួមទិញស្បែកគោទេ ។ រូបខ្លួនពុំបានរស់នៅក្បែររោងចក្រ គឺរស់នៅខេត្តតាកែវ ហើយស្បែកគោដែលឈ្មោះ [redacted] គង់ លក់ឲ្យ មានរាងបន្ទះពណ៌បៃតង ។ ស្បែកគោជាស្បែកដេរធ្វើស្បែកជើង រូបខ្លួនទើបតែទិញលើកទី១ និងកន្លងមកធ្លាប់ទិញកំទេចក្រណាត់ ហើយឈ្មោះ [redacted]គង់ និងឈ្មោះ [redacted] សារីយ៉ា យកស្បែកគោមកលក់ឲ្យខ្លួន ពុំបានដឹងថាស្បែកគោនេះបានមកពីណាទេ ទាល់តែឃាត់ខ្លួនទើបដឹងថា ស្បែកគោបានពីការលួចរោងចក្រ ។



Scanned with CamScanner

តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឈីវសុង ថា: នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង១១ និង៣០នាទី មុនកើតហេតុ ខ្លួនកំពុងនៅឯផ្ទះ ក៏បានទូរស័ព្ទពីសន្តិសុខរបស់រោងចក្រសាន់វើលប្រាប់ខ្លួនថា គាត់ឃើញសន្តិសុខរបស់រោងចក្រខ្លួន លីស្បែកគោយកទៅលាក់ទុកនៅមុខរោងចក្រ ស្ថិតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ នៅពេលនោះខ្លួនក៏មករោងចក្រទៅមើលសំភារៈស្បែកគោរក្នុងឃ្លាំងក៏បាត់អស់មួយចំនួន ហើយក៏សួរសន្តិសុខពីរនាក់ដែលយាមពេលយប់ ក៏បានសារភាពប្រាប់ថា ពិតជាបានយកស្បែកគោរបស់រោងចក្រមែន ។ បន្ទាប់មកខ្លួនក៏នាំសន្តិសុខទៅយកស្បែកគោដែលលាក់ទុកនៅចំណុចពីរមុខទ្វាររោងចក្រប្រហែល២០ម៉ែត្រ និងសួររកអ្នកទិញ ព្រោះកន្លងមកមានបាត់របស់ស្បែកគោក្នុងរោងចក្រជាច្រើន ។ ពេលនោះសន្តិសុខទាំងពីរនាក់នោះបានទូរស័ព្ទឲ្យអ្នកទិញមកទទួលទិញ ហើយក៏ឃើញអ្នកទិញទាំងពីរនាក់ជិះម៉ូតូម៉ាកសេ១០០ កូរ៉េ ពណ៌ក្រហមមកទិញរួច លើកស្បែកគោ២ដុំនោះដាក់លើម៉ូតូជិះបានប្រហែល២៥០ម៉ែត្រ ខ្លួនក៏បោះដៃឲ្យកូនចៅមកស្ទាក់ចាប់បាន រួចបញ្ជូនមកប៉ុស្តិ៍ ព្រមទាំងវត្ថុតាង ។

-តំណាងមហាអយ្យការសន្និដ្ឋានថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គង់ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សារីយ៉ា [redacted] ដេត និងសាក្សី ។ សុំក្រុមប្រឹក្សាពិចារណាតាមច្បាប់ សុំតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល ។

-មេធាវី [redacted] ហេង ការពារជនជាប់ចោទបានសន្និដ្ឋានថា: សកម្មភាពកូនក្តីខ្លួនធ្វើឡើងជាការមិនជាក់ស្តែងទេ ម្យ៉ាងកូនក្តីមានជីវភាពក្រីក្រ ខ្វះខាតប្រាក់ចាយ ហើយក៏បានឆ្លើយសារភាពដែរ សូមក្រុមប្រឹក្សាពិចារណាទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិនិត្យឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិចារណាត្រូវហើយ

## សាលាឧទ្ធរណ៍

១-យល់ឃើញថា បណ្តឹងឧទ្ធរណ៍លេខ:៨៥១ ចុះថ្ងៃទី២៥-១១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] គង់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ:១២៥ (ក្រ១) ចុះថ្ងៃទី២៧-១០-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបានយោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] គង់ សារភាពទទួលស្គាល់នូវអំពើល្មើសរបស់ខ្លួនថា ថ្ងៃកើតហេតុនោះខ្លួនមិនមែនអ្នកលួចទេ គ្រាន់តែជាអ្នកយកឥវ៉ាន់ពីជនជាប់ចោទ

[redacted] សារីយ៉ា យកទៅឱ្យជនជាប់ចោទឈ្មោះ [redacted] ដេត ជាអ្នកទិញ ។ ក៏ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ [redacted] សារីយ៉ា បានឆ្លើយនៅថ្ងៃទី ២៥-០៥-២០១០ ថាខ្លួននិងឈ្មោះ [redacted] គង់ បានលួចកង់ចំនួនមួយដុំយកទៅលក់អោយឈ្មោះ [redacted] ដេត បានប្រាក់ ៣០០០០រ ម្នាក់ៗ ។ តាមចម្លើយជនជាប់ចោទ [redacted] សារីយ៉ា តុលាការអាចយកជាការបាន ។

៣-យល់ឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទមានចេតនា ក្នុងការលួចយកទ្រព្យសម្បត្តិរបស់អ្នកដទៃ មកបំរើផលប្រយោជន៍របស់ខ្លួន ហើយជនជាប់ចោទទើបតែចូលធ្វើការក្នុងរោងចក្រនេះសោះ បែរជានាំគ្នាលួចយកទ្រព្យសម្បត្តិរោងចក្ររស់ជាច្រើនដង ។ អំពើបែបនេះ ពុំគួរអត់អោនបានឡើយ ទោះបីព្យសនកម្មកើតឡើងម្តងៗលក់មិនបានប្រាក់ច្រើនក៏ដោយ ។

៤-យល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ១២៥ (ក្រ១) ចុះថ្ងៃទី ២៧-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តី មានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ ហើយ គប្បីសាលាឧទ្ធរណ៍តម្កល់ទុកជាបានការ ។

**<u>ហេតុដូច្នេះ វិនិច្ឆ័យសេចក្តី</u>**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៨៥១ ចុះថ្ងៃទី ២៥-១១-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] គង់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១២៥ (ក្រ១) ចុះថ្ងៃទី ២៧-១០-២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] គង់ តាមច្បាប់ ។

៤-សាលដីកានេះ ជំនុំជម្រះជាសាធារណៈថ្ងៃទី ២៥-១០-២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ ជនជាប់ចោទឈ្មោះ [redacted] គង់ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកប្តឹងតវ៉ាក្នុងកំណត់ច្បាប់។

<u>សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលដីកានេះ អោយបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។</u>

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ជាន់ចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ៦ ខែ ៧ ឆ្នាំ២០១៤
ក្រឡាបញ្ជី

[redacted] [redacted]



Scanned with CamScanner